**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សូមគោរពជូន**
**ឯកឧត្តម សាយ ឈុំ**
**ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

***ឯកឧត្តមប្រធាន ជាទីគោរពដ៏ខ្ពង់ខ្ពស់***

ក្នុងឱកាសដ៏នក្ខត្តឫក្ស វិសេសវិសាល ប្រកបដោយមហាកិត្តិយសបំផុត ដែល**ឯកឧត្តម**ត្រូវបានអង្គព្រឹទ្ធសភាទាំងមូល បោះឆ្នោតជ្រើសតាំងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៥ ខ្ញុំបាទ និងករិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្មគ្រប់លំដាប់ថ្នាក់ សូមសម្តែងនូវអំណរសាទរយ៉ាងក្លៀវក្លាកក់ក្តៅបំផុត ប្រកបដោយមនោសញ្ចេតនារំភើបរីករាយក្រៃលែង ជូនចំពោះ **ឯកឧត្តមប្រធាន និងលោកជំទាវ** ព្រមទាំងក្រុមគ្រួសារទាំងអស់។

ខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នា មានជំនឿជឿជាក់យ៉ាងមុតមាំថា ក្រោមការដឹកនាំដ៏ឈ្លៀសវៃ ជាមួយនឹងភាពចាស់ទុំខាងនយោបាយ ព្រមទាំងសមត្ថភាព បទពិសោធន៍ការងារដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម** ស្ថាប័នព្រឹទ្ធសភានឹងបន្តទទួលបានជោគជ័យ រីកចម្រើន រឹងមាំថែមទៀត ដើម្បីរួមចំណែកក្នុងការពង្រឹងស្ថាប័ននីតិបញ្ញត្តិ ពង្រឹងនីតិរដ្ឋ ការកសាង អភិវឌ្ឍសេដ្ឋកិច្ច សង្គមជាតិលើគ្រប់វិស័យ និងការពារបានរដ្ឋធម្មនុញ្ញ ជាតិ សាសនា ព្រះមហាក្សត្រ ដែលជាបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជនកម្ពុជា។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុងឧត្តមនេះ ខ្ញុំបាទ និងករិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជូនចំពោះ**ឯកឧត្តមប្រធាន** និងសូមប្រសិទ្ធពរជ័យជូនចំពោះ **ឯកឧត្តមប្រធាន និងលោកជំទាវ** ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ទាំងអស់ សូមសមប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមប្រធានព្រឹទ្ធសភា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងកក្តីភាពដ៏ជ្រាលជ្រៅពីខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នា។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១៥
**តំណាងថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**ទេសរដ្ឋមន្ត្រី**

**ចម ប្រសិទ្ធ**